I

**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ២៣ **សាលដីកាប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៩៩ តុលាការកំពូល

សាលដីកា បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៣ខែ តុលាឆ្នាំ ១៩៩៩

លេខ ៣២ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី ១៣ខែតុលាឆ្នាំ១៩៩៩ ១- ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រមរបាយការណ៍

៥- លោក យស់ សួខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក ប៊ុល វណ្ណា

តំណាងមហាអយ្យការ

លោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ២១០ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

ពីបទ : ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រើប្រាស់អាវុធខុសច្បាប់ ភេរវកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១-១១-៩៥ ។

១- ជនជាប់ចោទឈ្មោះ អ៊ុក សឿន " ម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ កើតនៅ ភូមិ-ឃុំធំ ស្រុកល្វាឯម ខេត្តកណ្តាល មុខរបរ : អង្គភាពរថក្រោះ ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះសង់ថ្មី សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ អ៊ុក សឿន ( ស ) ម្តាយឈ្មោះ ពេញ ផន " រ " ប្រពន្ធឈ្មោះ សុំ គឹមសាន ។ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ៣០-៩-៩៦

- មានមេធាវីលោក លួង សុខា ការពារឱ្យជនជាប់ចោទ ។

២- ជនជាប់ចោទឈ្មោះ ជួង វុទ្ធី " ម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅ សង្កាត់លេខ៥ ក្រុងភ្នំពេញ ។ មុខរបរ : អនុបញ្ជាការកងរថក្រោះ ក្រសួងការពារជាតិ ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ ៣៣៣ ក្រុម៦ ផ្លូវ ១៦៣ សង្កាត់ទួលទំពូង២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

ឪពុកឈ្មោះ ជួង សំអាន ( ស ) ម្តាយឈ្មោះ ទូច ណៃ ( រ ) ប្រពន្ធឈ្មោះ មាស យីណា មានកូន ១នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៣-០១-៩៦ ។

មានមេធាវីលោក ខៀវ សុផល

៣- ជនជាប់ចោទឈ្មោះមៀវ មុន្នី ភេទប្រុស អាយុ២១ឆ្នាំជាតិខ្មែរ កើតនៅភូមិព្រែកលៀប ស្រុកពារាំង ខេត្តព្រៃវែង ។ ទីលំនៅផ្ទះលេខ ៨៩ ក្រុម ៤១ ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ។ ឪពុកឈ្មោះ មៀវ សាមិត ( រ ) ម្តាយឈ្មោះ ឈុន សៀវ ( រ ) នៅលីវ ទោសពីមុនគ្មាន ក្រៅឃុំ ។

មេធាវីគ្មាន

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ មឿង ហ៊ាង " ចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ លក់គ្រឿងអលង្ការ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ4 Eo សង្កាត់វត្តភ្នំ ក្រុម35 B ផ្លូវ 13 ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ ប៉ាក់ ហួយ ( ស ) ម្តាយឈ្មោះ មឿង អៀង ( រ ) ប្រពន្ធឈ្មោះ គង់ សំនៀង ។

- មេធាវី គ្មាន ។

- តាមបណ្តឹងសាទុក្ខលេខ ២៣ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ១៩៩៨ របស់ឈ្មោះជួង វុទ្ធី និងបណ្តឹងសាទុក្ខលេខ ៤៦ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះ អ៊ុក សឿន ដែលប្តឹងតវ៉ាពី សាលដីកាព្រហ្មទណ្ឌលេខ ២១០ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេច ទាំងមូល ។

- តាមកំណត់ហេតុយកចម្លើយ ជនជាប់ចោទឈ្មោះជួង វុទ្ធី ឆ្លើយនៅចៅក្រមស៊ើបអង្កេត ឆ្លើយថា ករណីចាប់ឈ្មោះ មឿង ហ៊ាង ខ្លួនពុំដឹងទេ ។ ចំពោះ ឡាន B M W នៅទួលគោកខ្លួននាំ PM ប៉ូលីសទៅយកនៅអង់តែនទូរទស្សន៍ និង វិទ្យុ ៩៩ មេកាហ៊ឺត របស់ឈ្មោះ អ៊ុក សឿន រកស៊ីចាប់មនុស្ស ទេ ។ ខ្លួនពុំស្គាល់ឈ្មោះ ចេម ដា ទេ ខ្លួនស្គាល់ មៀវ មុន្នី ដោយសារខ្លួនស្គាល់ម្តាយវា ហើយពុំដឹងថា វាធ្វើសកម្មភាពអ្វីទេ។ ខ្លួនពុំស្គាល់ឈ្មោះ ថន ទេ ពេលគេចាប់ខ្លួន គេដកឡាន កូរ៉ូណា ៨៩ ពណ៌កណ្តុរប្រផេះ ០១គ្រឿង វ៉ែនតារ៉ៃប៊ែន ១ និង លុយ 11.000 $ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់អយ្យការ អម តុលាការ ក្រុងភ្នំពេញ ថា :

ឆ្លងតាមសវនាការនេះ ទោះបីជនជាប់ចោទឈ្មោះ ជួង វុទ្ធី និង អ៊ុក សឿន ពុំបាន សារភាពពីអំពើ ដែលខ្លួនបានប្រព្រឹត្តបទ : ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ប្រើប្រាស់អាវុធខុសច្បាប់ និង អំពើ ភេរវកម្ម កាលពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ នៅក្រុងភ្នំពេញយ៉ាងណាក៏ដោយ ។ ប៉ុន្តែ យើងមាន មូលដ្ឋានគ្រប់គ្រាន់ ដោយផ្អែកតាមចម្លើយសារភាពជនជាប់ចោទឈ្មោះ ជួង វុទ្ធី នៅកងរាជអាវុធហត្ថ នៅ នគរបាលព្រហ្មទណ្ឌក្រុងភ្នំពេញ និង ចំលើយជនរងគ្រោះ ព្រមទាំងវត្ថុតាង និងឯកសារមួយចំនួន ឃើញថា ជនជាប់ចោទឈ្មោះ ជួង វុទ្ធី, អ៊ុក សឿន និង ឈ្មោះ មៀវ មុន្នី ពិតជាបានប្រព្រឹត្តបទ : ប្លន់ទ្រព្យ-

សម្បត្តិអ្នកដទៃប្រើប្រាស់អាវុធខុសច្បាប់ និងអំពើភេរវកម្មនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១-១១-១៩៩៥ ប្រាកដមែន ។ អំពើទាំងនេះ ល្មើសនឹងមាត្រាទី ៣៤, ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រាទី២ នៃច្បាប់ស្តីពីអំពើភេរវកម្ម ។ ហើយសូមឱ្យលោក ចៅក្រម ជំនុំជំរះផ្តន្ទាទោសជនជាប់ចោទទាំងបីនាក់ខាងលើនេះតាមច្បាប់ ។

- បានឃើញសាលក្រមលេខ 51 " គ " ចុះថ្ងៃទី 31-12-1997 របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ ដូចតទៅ :

១- ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ ជួង វុទ្ធី ភេទប្រុស អាយុ ៣៥ឆ្នាំ កំណត់ចំនួន ១៥ឆ្នាំ គិតចាប់តាំងពីថ្ងៃ ឃុំ ខ្លួន " ថ្ងៃឃុំខ្លួន 23-01-96 " និង ឈ្មោះ អ៊ុក សឿន ភេទប្រុស អាយុ២៧ឆ្នាំ កំណត់ចំនួន ១៥ឆ្នាំ គិតចាប់តាំងពីថ្ងៃ ឃុំខ្លួន " ថ្ងៃឃុំខ្លួន 30-9-96 " ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃប្រើប្រាស់អាវុធខុសច្បាប់ និង អំពើភេរវកម្ម " ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី 01-11-95 តាមបញ្ញត្តិមាត្រា ៣៤, ៥៤ នៃក្រមព្រហ្មទណ្ឌអន្តរកាល និង មាត្រា ២ នៃច្បាប់ស្តីពីអំពើភេរវកម្ម ។

២- បង្គាប់ឱ្យភ្នាក់ងារមានសមត្ថកិច្ចស្វែងរកចាប់ខ្លួនឈ្មោះ មៀវ មុន្នី ភេទប្រុស អាយុ ២១ឆ្នាំ ទីលំនៅ ផ្ទះលេខ 89 ក្រុម41 ផ្លូវព្រះសុធារស សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ និង ឱ្យដាក់ពន្ធនាគារឈ្មោះ នេះ ចំនួន ១៥ឆ្នាំ គិតចាប់តាំងពីថ្ងៃចាប់ខ្លួនបាន ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃប្រើប្រាស់អាវុធខុសច្បាប់ និង អំពើភេរវកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី 01-11-95 តាមបញ្ញត្តមាត្រាទី ៣៤, ៥៤ នៃក្រមព្រហ្មទណ្ឌអន្តរកាល និង មាត្រា ២ នៃច្បាប់ស្តីពីអំពើភេរវកម្ម ។

៣- វត្ថុតាងមាន : អាវុធបេ៤០ មួយដើម គ្រាប់ដប់ គ្រាប់អាវុធវែងម៉ាក អ៊ែរប៉េដេ ០១ដើម អាវុធវែងម៉ាកប៉េកាអ៊ឹមអេស ០១ដើម គ្រាប់កាំភ្លើងកា ៥៧ បីកេស គ្រាប់បែកដៃ ០៤គ្រាប់ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។ ដោយឡែកផ្លាករថយន្តបីរឹបអូសបំផ្លាញចោល ។

៤- បង្គាប់ឱ្យឈ្មោះ ជួង វុទ្ធី, អ៊ុក សឿន និង ឈ្មោះ មៀវ មុន្នី រួមសងប្រាក់ចំនួន 772.320$ នាឡិកាម៉ាក់រ៉ូឡិច ០១គ្រឿង ចិញ្ចៀនពេជ្រ ០១វង់ មានតំលៃ ៣ម៉ឺន ដុល្លា ផ្កាក់ដៃពេជ្រ មួយខ្សែ មានតំលៃ 7.000 $ ទៅឈ្មោះ មឿង ហ៊ាង វិញ ។ ក្នុងករណីរឹងទទឹងមិនព្រមសង ត្រូវដាក់គុកបង្ខំលើរូបកាយ នឹងរឹបអូសទ្រព្យសម្បត្តិតាមច្បាប់ ស្តីពីការដាក់គុកបង្ខំលើរូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ។

៥- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះជួង វុទ្ធី, អ៊ុក សឿន កំបាំងមុខជនជាប់ចោទឈ្មោះ មៀវ មុន្នី សំរេចបើកផ្លូវឧទ្ធរណ៍ និង ប្តឹងទាស់ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤៣ " គ " ចុះថ្ងៃទី ៧-១០-៩៧, បណ្តឹងឧទ្ធរណ៍លេខ ៤៥ " គ " ចុះថ្ងៃទី ២៤-១០-៩៧ និង ឧទ្ធរណ៍ លេខ ៤៦ " គ " ចុះថ្ងៃទី ២៤-១០-៩៧ របស់មេធាវី ឈ្មោះ ( ទេស សាមឿន, សម មុន្នីកា និង មេធាវីឈ្មោះ ចុង អៀវហេង ) ដែលប្តឹងតវ៉ាពីសាលក្រមលេខ 51 " គ " ចុះថ្ងៃទី 19-9-1997 លើសេចក្តីសំរេចទាំងមូល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ថា :

សូមផ្អែកលើលិខិតកោសល្យវិច្ច័យពេទ្យ ជាផ្លូវការទាំងស្រុង ។

តម្កល់សាលក្រមរបស់តុលាការក្រុងភ្នំពេញទុកជាបានការហើយ ចំណុចទី២ នៃសាលក្រម សូមក្រុមប្រឹក្សាពិនិត្យពិចារណាលើលិខិតពេទ្យរបស់ឈ្មោះ មៀវ មុន្នី ដែលខាងជំនាញចេញជាផ្លូវការដូច្នេះ ត្រូវទទួលស្គាល់តាមផ្លូវច្បាប់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ២១០ ចុះថ្ងៃទី ១៦-៩-៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១/-ក- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៣ " គ " ចុះថ្ងៃទី ៧-១០-៩៧ របស់មេធាវីឈ្មោះ ចុង អៀវហេង ការពារឱ្យឈ្មោះ ជួង វុទ្ធី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

ខ- ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៥ " គ " ចុះថ្ងៃទី ២៤-១០-៩៧ របស់ឈ្មោះទេស-សាមឿន អ្នកការពារឱ្យឈ្មោះ មៀវ មុន្នី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

គ- ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤៦ " គ " ចុះថ្ងៃទី ២៤-១០-៩៧ របស់ឈ្មោះ សម-មុន្នីកា អ្នកការពារឱ្យឈ្មោះ អ៊ុក សឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២- តម្កល់សាក្រមព្រហ្មទណ្ឌលេខ ៥១ " គ " ចុះថ្ងៃទី ១៩-៩-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ប៉ុន្តែលើកលែងចំណុចទី១ , ទី២ ត្រូវកែប្រែជា :

ក- ផ្តន្ទាទោសឈ្មោះ អ៊ុក សឿន ភេទប្រុស អាយុ ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ " ដប់ឆ្នាំ " គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ៣០-០១-១៩៩៦ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ , ប្រើប្រាស់អាវុធខុសច្បាប់ និង អំពើភេវរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១-១១-១៩៩៥ តាមបញ្ញត្តិមាត្រា ៣៤ , ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២ និង មាត្រា២ នៃច្បាប់ស្តីពីភេវរកម្ម ។

ខ- ផ្តន្ទាទោសឈ្មោះ ជួង វុទ្ធី ភេទប្រុស អាយុ ៣៥ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ " ដប់ឆ្នាំ " គិតពីថ្ងៃ ឃុំខ្លួន ថ្ងៃទី ២៣-០១-១៩៩៦ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ , ប្រើប្រាស់អាវុធខុសច្បាប់ និងអំពើភេវរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០១-១១-១៩៩៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤-៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២ និង មាត្រា ២ នៃច្បាប់ស្តីពីភេវរកម្ម ។

គ- ផ្តន្ទាទោសឈ្មោះ មៀវ មុន្នី ភេទប្រុស អាយុ២៤ឆ្នាំ ដាក់ពន្ធនាគារកំណត់២ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរ ដោយកំណត់រយៈពេលសាកល្បង ៥ឆ្នាំ ចាប់គិតពីថ្ងៃដែលសាលដីកានេះ ចូលជាស្ថាពរពីបទ : ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ , ប្រើប្រាស់អាវុធខុសច្បាប់ និងអំពើភេវរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១-១១-៩៥ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤-៥៤-៦៨ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២ និងមាត្រា ២ នៃច្បាប់ស្តីពី

ភេវរកម្ម ។

៣- សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឈ្មោះជួង រ៉ុទ្ធី ឈ្មោះ អ៊ុក សឿន កំបាំងមុខជនជាប់ចោទឈ្មោះ មៀវ មុន្នី និង ដើមបណ្តឹងរដ្ឋប្បវេណី ។

សំរេចបើកផ្លូវប្តឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៣ ចុះថ្ងៃទី ២០-១០-១៩៩៨ របស់ឈ្មោះ ជួង រ៉ុទ្ធី និងបណ្តឹងសាទុក្ខលេខ៤៦ ចុះថ្ងៃទី ២២-១០-១៩៩៨ របស់ឈ្មោះ អ៊ុក សឿន ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២១០ ចុះថ្ងៃទី ១៦-៩-១៩៩៨ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី ២១-០៥-១៩៩៩ របស់មេធាវីឈ្មោះ ខៀវ សុផល ការពារឱ្យឈ្មោះ ជួង រ៉ុទ្ធី ជាម្ចាស់បណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ " ។

- បានឃើញសារណា ចុះថ្ងៃទី ១៦-៥-១៩៩៩ របស់ឈ្មោះ អ៊ុក សឿន ជាម្ចាស់បណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ " ។

- បានឃើញសេចក្តីបញ្ជាក់របស់ប្រធានភូមិទី៩ សង្កាត់វត្តភ្នំ លើលិខិតបង្គាប់ឱ្យធ្វើសារណារបស់តុលាការកំពូល ថា ឈ្មោះ មឿង ហ៊ាង បានលក់ផ្ទះចេញពីសង្កាត់វត្តភ្នំ តាំងពីដើមឆ្នាំ ១៩៩៨ មេ្លះ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

១- បណ្តឹងសាទុក្ខរបស់ឈ្មោះ ជួង រ៉ុទ្ធី និង អ៊ុក សឿន ស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយករឿងនេះ មកពិនិត្យ ពិចារណា ។

២- ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២១០ ចុះថ្ងៃទី ១៦-៩-៩៩ របស់សាលាឧទ្ធរណ៍ ។

- ក្រឡាបញ្ជីអានសារណា របស់ជនជាប់ចោទឈ្មោះ អ៊ុក សឿន

- ក្រឡាបញ្ជីអានសារណា របស់ជនជាប់ចោទឈ្មោះ ជួង រ៉ុទ្ធី

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ខៀវ សុផល ការពារឱ្យជនជាប់ចោទឈ្មោះ ជួង រ៉ុទ្ធី ថា : យល់ឃើញថា កូនក្តីខ្ញុំបាទឈ្មោះ ជួង រ៉ុទ្ធី ពុំបានប្រព្រឹត្តអំពើទាំងឡាយ ដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាឡើយ ផ្ទុយទៅវិញ កូនក្តីខ្ញុំបាទជាមនុស្សសុទ្ធចិត្តល្អណាស់ ។ ការដែលប៉ូលីសចាប់កូនក្តីខ្ញុំបាទដាក់គុក តាំងពីឆ្នាំ១៩៩៥ រហូតដល់សព្វថ្ងៃ គឺបណ្តាលមកពីការគុំគួនគ្នារវាងប៉ូលីស និង កូនក្តី ខ្ញុំបាទតែប៉ុណ្ណោះ ។

ម៉្យាងទៀតកូនក្តីខ្ញុំបាទ មានឋានន្តរៈសក្តិជានាយទាហានជាន់ខ្ពស់ ខាងកងរថក្រោះ ដែលធ្លាប់ធ្វើការបំរើជាតិ និង ការពារជាតិធ្វើឱ្យប្រជារាស្ត្របានសុខសាន្តរហូតមក តើមានហេតុផលអ្វី ដែលចោទកូនក្តីខ្ញុំបាទដូច្នេះទៅវិញ ។

អាស្រ័យហេតុនេះ សូមតុលាការមេត្តាពិចារណា ។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក លួង សុខា ការពារឱ្យជនជាប់ចោទឈ្មោះ អ៊ុក សឿន ថា : កូនក្តី របស់ខ្ញុំបាទឈ្មោះ អ៊ុក សឿន ពុំដែលស្គាល់ឈ្មោះ មៀវ មុន្នី ឡើយ រាល់ការកើតហេតុ អំពើចាប់ជំរិតនេះ គឺធ្វើឡើងនៅភ្នំពេញ តែឈ្មោះ អ៊ុក សឿន នៅឯបាត់ដំបងជាមួយម្តាយរបស់ខ្លួន តាំងពីមុនថ្ងៃកើតហេតុ ។ សុំឱ្យកូនក្តីរបស់ខ្ញុំបាទ រួចពីការចោទប្រកាន់ និង សុំឱ្យដោះលែង ។

- តំណាងមហាអយ្យការ សូមរក្សាទុក នូវសេចក្តីសន្និដ្ឋាននៅដដែល ។
    - ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
    - ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
    - ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី ជនជាប់ចោទ .
    - ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៣ ចុះថ្ងៃទី ២០-១០-៩៨ របស់ឈ្មោះ ជួង វុទ្ធី និង បណ្តឹងសាទុក្ខលេខ ៤៦ ចុះថ្ងៃទី ២២-១០-៩៨ របស់ឈ្មោះ អ៊ុក សឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ក្នុងការសួរចម្លើយជនជាប់ចោទឈ្មោះ ជួង វុទ្ធី នៅកងរាជអាវុធហត្ថ និង នៅនគរបាលព្រហ្មទណ្ឌ ពុំមានវត្តមានមេធាវី ដូច្នេះការសួរចម្លើយជនជាប់ចោទពីបទឧក្រិដ្ឋ ដោយពុំមានវត្តមានមេធាវីនោះ គឺជាការរំលោភទៅលើមាត្រា ៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និង មាត្រា១០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហើយភស្តុតាង ប្រភេទនេះ ពុំប្រាកដថា ជាការត្រឹមត្រូវឡើយ ។

- យល់ឃើញថា ជនរងគ្រោះក្តី ជនជាប់ចោទ ផ្សេងទៀតក្តី ពុំបានឆ្លើយដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ ជួង វុទ្ធី ដែរ ។

- យល់ឃើញថា ក្រៅពីភស្តុតាង តាមរយៈការសួរចម្លើយជនជាប់ចោទឈ្មោះ ជួង វុទ្ធី នៅកងរាជអាវុធហត្ថ និង នៅនគរបាលព្រហ្មទណ្ឌចេញ ពុំមានចម្លើយណាមួយរបស់ជនរងគ្រោះ និង ជនជាប់ចោទផ្សេងទៀត ឆ្លើយដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ អ៊ុក សឿន ឡើយ ។

- យល់ឃើញថា ជនជាប់ចោទឈ្មោះ មៀវ មុន្នី ដែលត្រូវបានជនរងគ្រោះ និង ជនជាប់ចោទផ្សេងទៀតឆ្លើយដាក់ បែរជាពុំត្រូវបានកងរាជអាវុធហត្ថ ឬនគរបាលព្រហ្មទណ្ឌ ឬអាជ្ញាធរតុលាការធ្វើការសាកសួរឡើយ ម្យ៉ាងទៀត ទាំងតុលាការក្រុងភ្នំពេញ ទាំងសាលាឧទ្ធរណ៍ ក៏ពុំបានផ្ទៀងផ្ទាត់អំពីវត្តមាន

ជាមធ្យោបាយសំរាប់ធ្វើសកម្មភាពប្រព្រឹត្តបទល្មើសដែរ ដែលជាការខ្វះខាត គប្បីតុលាការធ្វើការស៊ើបអង្កេតបន្ថែមទៀត ។

- យល់ឃើញថា ជនជាប់ចោទ បានធ្វើសារណាជូនមក តុលាការកំពូល និង បានទទួលដីកាកោះហើយ ចំណែកដើមបណ្តឹងរដ្ឋប្បវេណី ពុំបានធ្វើសារណាជូនមកតុលាការកំពូលទេ ប៉ុន្តែនៅលើលិខិតបង្គាប់ឱ្យធ្វើសារណា ប្រធានសង្កាត់វត្តភ្នំបានបញ្ជាក់ថា ឈ្មោះ មឿង ហ៊ាង បានលក់ផ្ទះចេញពីសង្កាត់វត្តភ្នំតាំងពីដើមឆ្នាំ១៩៩៨ម្លេះ ហើយទាំងជនជាប់ចោទ ទាំងដើមបណ្តឹងរដ្ឋប្បវេណី ពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២១០ ចុះថ្ងៃទី ១៦-៩-៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខ មេធាវី ជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និង

ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ.

១- ទទួលបណ្តឹងសាទុក្ខលេខ ៤៣ ចុះថ្ងៃទី ២០-១០-៩៨ របស់ឈ្មោះ ជួង វុទ្ធី និង បណ្តឹងសាទុក្ខលេខ ៤៦ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៨ របស់ឈ្មោះ អ៊ុក សឿន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២១០ ចុះថ្ងៃទី ១៦-៩-៩៨ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី ១០-៥-៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ១៩៩៩ ។